# ស្ថានទូតអូស្ត្រាលី
# រាជធានីភ្នំពេញ

## សេចក្តីប្រកាសពត៌មាន

## គំរោង "Best Angkor Sunsets" ត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់

នៅក្នុងចំណុចសំខាន់ដ៏ចំបងមួយសំរាប់គំរោងក្របខណ្ឌគ្រប់គ្រងបេតិកភ័ណ្ឌអង្គរ កាលពីថ្ងៃសុក្រ ទី២៨ ខែមិថុនា អាជ្ញាធរអប្សរាបានសម្ពោធដាក់អោយប្រើប្រាស់នូវគំរោង "Best Angkor Sunsets" ដែលជាគំនិតផ្តួចផ្តើមមួយដោយរួមមានការបង្កើតគេហទំព័រថ្មីមួយ និងប័ណ្ណពត៌មានដែលរៀបចំឡើងដើម្បីគាំទ្រដល់ការអភិរក្សតំបន់អង្គរដើម្បីបំពេញតាមតំរូវការរបស់ភ្នាក់ងារទេសចរណ៍ និងអ្នកទេសចរណ៍ ។

រដ្ឋាភិបាលអូស្ត្រាលី និង រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីអង្គការយូនីស្កូ បានផ្តួចផ្តើមបង្កើតឡើងនូវគំរោងក្របខណ្ឌបេតិកភ័ណ្ឌក្នុងឆ្នាំ២០០៨ ដើម្បីឆ្លើយតបទៅនឹងការរីកចំរើនឥតឈប់ឈរក្នុងវិស័យទេសចរណ៍ ការប្រឈមបរិស្ថានថ្មីៗ និងការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សរបស់សហគមន៍ដែលនៅក្បែរតំបន់បេតិកភ័ណ្ឌពិភពលោកអង្គរ។ គំនិតផ្តួចផ្តើម "Best Angkor Sunsets" គឺជាគំរោងមួយក្នុងចំណោមគំរោងសាកល្បងទាំងបួនដែលបង្កើតឡើងក្រោមគំរោងក្របខណ្ឌគ្រប់គ្រងបេតិកភ័ណ្ឌ។

គំរោង "Best Angkor Sunsets" បានកំណត់ជាជម្រើសបន្ថែមមួយចំនួនក្នុងការទស្សនាថ្ងៃលិច ដែលជួយធ្វើអោយមានភាពប្រសើរឡើងដល់ការគ្រប់គ្រងលំហូរនៃអ្នកទេសចរណ៍ ផ្តល់បទពិសោធន៍ថ្មី និងការរីករាយទស្សនាជាងមុនសំរាប់អ្នកទេសចរណ៍ និងចូលរួមចំណែកក្នុងការអភិរក្សប្រាង្គប្រាសាទបានល្អប្រសើរជាងមុន ដែលនេះគឺជាការបង្ហាញនូវគោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំងឡាយ ដែលរៀបចំឡើងដោយអាជ្ញាធរអប្សរាក្នុងការគ្រប់គ្រងតំបន់បេតិកភ័ណ្ឌពិភពលោកអង្គរ។

គេហទំព័រថ្មីនិងប័ណ្ណពត៌មាននេះ ត្រូវបានរៀបចំឡើងដោយទីប្រឹក្សាអូស្ត្រាលីរបស់ក្រុមហ៊ុន Godden Mackay Logan (GML) ដោយសហការជាមួយអាជ្ញាធរអប្សរា និងអង្គការយូនីស្កូ ដែលនេះជាផ្នែកមួយនៃគំរោងក្របខ័ណ្ឌគ្រប់គ្រងបេតិកភ័ណ្ឌអង្គរ។

No 16B, National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

សាស្ត្រាចារ្យ Richard Mackay ដែលមកពី ក្រុមហ៊ុន Godden Mackay Logan (GML) បានពន្យល់ថា ក្នុងពេលទស្សនាប្រាសាទអង្គរ ការទស្សនាថ្ងៃលិច ជានិច្ចកាលគឺជាទិសដៅចំបងនៃអ្នកទេសចរណ៍ និងជាបទពិសោធន៍សំខាន់មួយសំរាប់អ្នកទេសចរណ៍។ ប៉ុន្តែបច្ចុប្បន្ននេះ អ្នកទេសចរណ៍អាចទទួលបាននូវបទពិសោធន៍នេះតែក្នុងទីតាំងមួយចំនួនតូចតែប៉ុណ្ណោះ។ ជាលទ្ធផល ទីតាំងទស្សនាតែងតែមានភាពចង្អៀតណែន។

សាស្ត្រាចារ្យ Richard Mackay បានមានប្រសាសន៍ថា "ទីកន្លែងទស្សនាថ្ងៃលិចដែលមានភាពចង្អៀតអាចបណ្តាលអោយមានផលប៉ះពាល់ដល់ទីតាំងនោះ ហើយកាត់បន្ថយនូវគុណភាពនៃបទពិសោធន៍អ្នកទេសចរណ៍" ។

គំរោង "Best Angkor Sunsets" ផ្តល់ជូននូវជំរើសទស្សនាថ្ងៃលិចនៅអង្គររហូតដល់ ៣០ទីតាំងជូនអ្នកទេសចរណ៍។ គេហទំព័រថ្ងៃលិចនៅអង្គរ (www.angkorsunsets.com) អាចជួយអោយអ្នកទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ស្រាវជ្រាវតាមជំរើសនៃការទស្សនាថ្ងៃលិច តាមតំរូវការផ្សេងៗ។

រដ្ឋាភិបាលអូស្រ្តាលី មានសេចក្តីរីករាយដោយបានគាំទ្រដល់គំនិតផ្តួចផ្តើមដ៏មានសារសំខាន់នេះ៕


***សំរាប់ពត៌មានបន្ថែមសូមទាក់ទង:***

លោក **ដេវ ហ្គោច** (Dave Gordge) អ្នកនាំពាក្យនៃស្ថានទូតអូស្រ្តាលី
ប្រចាំរាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០២៣ ២១៣ ៩៧០ លេខបន្ត: ៥០២


ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ ២០១៣